-ពិនិត្យចំនួនលក្ខណសម្បត្តិ មន្ត្រីរាជការ ទាំងឡាយដែលក្រសួង ស្ថាប័នរដ្ឋនានា ស្នើសុំ គ្រឿងឥស្សរិយយស

-ពិនិត្យ សំរេច និងធ្វើសំណើជាកំណត់ជូនសម្តេចនាយករដ្ឋមន្ត្រី ដើម្បីប្រគល់គ្រឿងឥស្សរិយយស តាមចំណាត់ថ្នាក់ ដែលបានបំពេញការងារដើម្បីជាប្រយោជន៍ជាតិ

-ធ្វើសំណើសុំគ្រឿងឥស្សរិយយសជូន មន្ត្រីរាជការ រៀងរាល់ ២ ឆ្នាំម្តង ។

មាត្រា ៤ ._

គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតអោយមានគណៈកម្មការមួយ ដើម្បីពិនិត្យលក្ខណសម្បត្តិ បុគ្គលដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស ដែលមានថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ធ្វើជាប្រធានគណៈកម្មការ និង ថ្នាក់ដឹកនាំអង្គភាពសំខាន់ៗ ក្រោមឱវាទក្រសួង ស្ថាប័ន ជាសមាជិក ហើយបញ្ជូនបញ្ជីបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយសទាំងនោះមកគណៈកម្មការពិនិត្យលក្ខណសម្បត្តិរបស់ មន្ត្រីរាជការ ដែលត្រូវផ្តល់ជូនគ្រឿងឥស្សរិយយស ។

មាត្រា ៥ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងសមាសភាពគណៈកម្មការ ដូចមានចែងក្នុងមាត្រា ២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

**អនុក្រឹត្យលេខ ៦៧ អនក្រ.បក**

**ស្តីពីការលុបអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០០**

**ស្តីពីការកាត់ព្រំប្រទល់ដី និងសំណង់ នៅតំបន់ សៀមរាប អង្គរ**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ ០៥/នស/ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត អាជ្ញាធរជាតិឲ្យការពារតំបន់ និងរៀបចំដែនដីតំបន់អង្គរ ដែលរួមនៅតាមព្រះរាជក្រឹត្យ លេខ នស/០១៩៩/១៨ ចុះថ្ងៃទី២២ ខែ មករា ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ៧៩/អនក្រ.បក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ១៩៩៥ ស្តីអំពីបរិ សណ្ឋាគារ និងអនុក្រឹត្យលេខ ៩៣/អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរ ផ្ទៃដីប្រើសម្រាប់អង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា
- តាមសំណើរបស់ក្រុមភិបាលនៃការអភិវឌ្ឍន៍នៅតំបន់សៀមរាប អង្គរ

**សម្រេច**

**មាត្រា ១ .-** ត្រូវចាត់ទុកជានិរាករណ៍ អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី១២ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការប្រើប្រាស់ដីធ្លី និងសំណង់ នៅតំបន់សៀមរាប អង្គរ ។

**មាត្រា ២ .-** ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំគម្រោងថ្មីនូវអនុក្រឹត្យ ស្តីពីការប្រើប្រាស់ដីធ្លី និងសំណង់ នៅតំបន់សៀមរាប អង្គរ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីអាណាព្យាបាលអាជ្ញាធរអប្សរា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលខេត្តសៀមរាប គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

www.pheakdeylaw.com